# រឿង មហាចោរនៅទល់ដែន

**ភាគទី៦៦** (ក្បួនការពារឯកពជ្យ)

អារុណមកកាន់ដៃមានន្ទនិយាយថា:

ខ្ញុំនឹកលោកគ្រូណាស់!

មានន្ទសើច:

ខ្ញុំអរគុណអារុណណាស់!

អារុណសើច:

ចុះហេតុម៉េច បានជាលោកគ្រូមិនឲ្យពួកយើងសម្លាប់និលពេជ្រចោលទៅ?

ពីព្រោះបើអារុណឯងសម្លាប់ ធ្វើម៉េចខ្ញុំបានសម្លាប់។ ខ្ញុំបានសន្យាជាដាច់ខាតថា ខ្ញុំនឹងសម្លាប់និលពេជ្រដោយដៃខ្ញុំ។

វីរៈ នាយកត នាយឡុំ មហាកាល អារុណស្រែកដំណាលគ្នា:

ឱ! បើដូចនោះ សូមលាលោកគ្រូហើយ។

មហាកាលបន្ថែមខ្សឹបៗទៀតថា:

យើងទៅលួចសេះព្រះកម្ពុតជិះទៅសិរីសោភ័ណទាន់។

នាយកតនិយាយខិបខុបថា:

ខ្ញុំបានស្គាល់កន្លែងពួកវាបម្រុងយកមាសទៅលាក់ហើយ គឺលាក់ក្នុងភ្នំដែលឆ្នាំមុនខ្ញុំធ្លាក់អណ្តូងនោះឯង។

វីរៈតបថា:

បើដូច្នោះ យើងទៅចាំវានៅមាត់ច្រកភ្នំបានហើយ។

អារុណប្រាប់គេប្រាប់ឯង:

ជយោ! ទៅកុំនៅយូរវាខូចការ លាហើយលោកគ្រូ!

អត្ថបទដោយ៖ មាស សុភាព

និលពេជ្រដែលនៅឆ្ងាយពីគេ ឃើញគេខ្សឹបខ្សៀបគ្នាក៏រឹតតែភ័យទៅទៀត ដោយមិនដឹងជាគេនិយាយពីរឿងអ្វីឡើយ។

ជនទាំងប្រាំគោរពមានទន្សូបចេញដំណើរទៅ។ មានទន្សំរាកទៅរកនិលពេជ្រនិយាយយ៉ាងនឹងនួនថា:

បងនិល

ព្រះបាទទាន!

បងនិលឯងចង់សម្លាប់ខ្ញុំ ឥឡូវមកសម្លាប់ចុះ។

ខ្ញុំរង់ចាំពេលក្រោយបន្តិចទៀតសិន!

អញ្ចឹងក៏បាន! ឥតទាស់អ្វីទេ ឯខ្ញុំក៏ចង់សម្លាប់បងនិលឯងដែរហើយខ្ញុំចង់តែសម្លាប់ពេលនេះឯង!

សូមលោកគ្រូកុំភ័យ ប្រាកដជាយើងបានជួបគ្នាទាន!

មិនទៀងទេ!

លោកគ្រូនឹកស្មានថា ខ្ញុំមិនហ៊ានចាក់ជាមួយលោកគ្រូឬ?

ទេ! ទេ! ខ្ញុំទុកបងនិលឯងជាមនុស្សក្លាហានទៅហើយ។ ប៉ុន្តែបានជាខ្ញុំចង់ពេលនេះ ពីព្រោះខ្ញុំអាចស្លាប់នឹងដៃអ្នកឯទៀតមុនពេលដែលខ្ញុំសម្លាប់បងឯង។

និលពេជ្រញញឹម:

បើពីឥឡូវនេះទៅដល់ពេលដែលហយើងណាត់ជួបលោកគ្រូស្លាប់ គឺជាសេចក្តីស្តាយមួយយ៉ាងធំរបស់ខ្ញុំ។

បើដូច្នោះតើអ្វីដែលបង្អាប់មិនឲ្យបងឯងមានចិត្តចង់អោយស្លាប់ក្នុងពេលនេះ?

ពីព្រោះខ្ញុំមានមិត្តបួន គឺខ្ញុំមួយ ឯកនេះពីរ មហារន្ទះនេះបី និងលោកកាមានេះបួន។ យើងទាំងបួនសន្យានឹងគ្នាថា សម្លាប់លោកគ្រូឲ្យបានជាមួយគ្នា។ បើក្នុងពេលនេះ ខ្ញុំសម្លាប់លោកគ្រូម្នាក់ឯងទៅគឺខ្ញុំក្បត់មិត្តទាំងបីនាក់ទៀត។

សម្លាប់ខ្ញុំយ៉ាងណាទៅដល់ទៅបួននាក់ បើខ្ញុំម្នាក់ឯង។

អត្ថបទដោយ៖ មាស សុភាព

*ងាយណាស់។ ខ្ញុំកាត់ក្បាលលោកគ្រូ ឯកគេវះយកថ្លើមប្រមាត់ រន្ទះគេកាត់ដៃ និងជើងលោកកាមាគេហុតឈាមលោកគ្រូ។*

*និលពេជ្រប្រហែលជាខឹងណាស់ ពីព្រោះគេឮសូរឆ្មេញដែលសង្កៀតគ្នា រួចនិយាយទៅទៀតថា:*

*ហេតុនេះសូមលោកគ្រូរងចាំបន្តិចទៀតចុះ រង់ចាំពេលគឺថ្ងៃដែលយើងទាំងបួននាក់ដាក់ដៃលើលោកគ្រូនោះឯង!*

*ខ្ញុំប្រឹងរងចាំថ្ងៃនោះប្រាកដ ប៉ុន្តែខ្ញុំបារម្ភខ្លាចក្រែងខ្ញុំមិនបានរស់ដល់ថ្ងៃដែល យើងត្រូវជួបគ្នានោះ។ ខ្ញុំគិតឃើញថា ពេជ្រឯងត្រូវតែឆ្លៀតឱកាសល្អដែលយើងបានជួបគ្នានេះ។*

*ទេ!*

*ឯងខ្លាចស្លាប់ឬ? ហាស់ៗ និលពេជ្រខ្លាចស្លាប់! មិនអីទេចាំពេលក្រោយក៏បាន!*

*ថាតែប៉ុណ្ណោះ មានន្ទលោតផ្លោតតាមបង្អួចចូលបាត់ក្នុងគុម្ពចេកទៅ។ មនុស្សចាស់ម្នាក់ស្ទុះមកចាប់ដៃមានន្ទ ដែលឆ្លើយថា:*

*បាទ! អញ្ជើញលោកគ្រូ!*

*គឺតាគីរីសុមេរុ ដែលចំនួនមួយអាទិត្យមកហើយ បានដើរតាមមានន្ទ*

*ទៅចៅ! ចេញពីទីនេះឲ្យឆាប់ៗ ត្បិតខ្យល់នៅទីនេះមិនល្អចំពោះយើងទេ។ មិនអីទេ! គង់យើងបានជួបនឹងពួកវាមិនខាន។*

*លោកតាបានឮខ្ញុំនិយាយនឹងនិលពេជ្រទេ?*

*ឮទាំងអស់ តាចាំស្តាប់ក្រោមផ្ទះនេះឯង។*

*ជនទាំងពីរចាប់ដៃគ្នា ដើរយ៉ាងលឿនចេញទៅទិសខាងសិរិសោភ័ណវិញ បីដូចពួកម៉ាកពីរនាក់ដែលស្រលាញ់គ្នាជីវិតមួយ។*

*ចំណែកខាងនិលពេជ្រកាលណាបានឃើញមានន្ទចុះបាត់ហើយ ក៏ស្ទុះរត់ចេញដើរបោលទៅឯកងទ័ពហៅបានមិត្តគេទាំងបួនមកមួរំពេច។ មិត្តទាំងបួននេះ ដេញតាមមានន្ទឆ្វាយចូលមកតាមច្រកគុម្ពចេក ដែលមានន្ទគៀសខ្លួនទៅ។ និលពេជ្រ សួរអ្នកស្រុកម្នាក់ថា:*

*វាទៅណាហើយ?*

*អត្ថបទដោយ៖ មាស សុភាព*

ខ្ញុំមិនដឹងជាគេទៅណាទេ ប៉ុន្តែដែលខ្ញុំដឹង គឺគេទៅបាត់ទៅហើយ! ហើយប្រហែលជាមិនជិតឡើយ!

មិត្តទាំងបួនបញ្ចូលដាវក្នុងស្រោមវិញ ដោយពោលថា:

គង់តែយើងជួបនឹងវាទេ ថ្ងៃក្រោយ! អានេះវាចូលដៃនឹងខ្លាំងទៀត រួចមិនប្រាប់ឯង។

ពិតមែនមិត្តទាំងបួនបានប្ដេជ្ញា ថានឹងសម្លាប់មានន្ទដោយបែបខាងលើនោះឯង ហើយសន្មតគ្នាថា មិនសម្លាប់មានន្ទម្នាក់ឯងឡើយ។

**(សូមរង់ចាំតាមដានភាគទី៦៧ នៅសប្ដាហ៍ក្រោយ)**

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព